PTI0069

សម្ភាសន៍ជាមួយឈ្មោះ យូ ធី ភេទស្រី អាយុ៤៩ឆ្នាំ
រស់នៅភូមិប្រមោយ ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់
មុខងារសម័យខ្មែរក្រហមៈ សិល្បករ
មុខងារបច្ចុប្បន្នៈ ធ្វើចំការ
សម្ភាសន៍ដោយៈ សោម ប៊ុនថន
សម្ភាសន៍ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១
សរុបទំព័រៈ ២៤
០០:៤៦:៤២

ប៊ុនថនៈ អញ្ជើញខ្ញុំសុំអនុញ្ញាតិសួរឈ្មោះមីង តើមីងឈ្មោះអីដែរ?

ធីៈ ខ្ញុំឈ្មោះ យូ ធី ។

ប៊ុនថនៈ មីងអាយុប៉ុន្មានហើយ?

ធីៈ ខ្ញុំអាយុ៤៩ឆ្នាំ ។

ប៊ុនថនៈ មីងមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ធីៈ ស្រុកកំណើតខ្ញុំនៅកោះកុង ។

ប៊ុនថនៈ ភូមិអីដែរមីង?

ធីៈ ភូមិដងពែង ឃុំដងពែង ។

ប៊ុនថនៈ ស្រុក?

ធីៈ ស្រុកស្រែអំបិល ។

ប៊ុនថនៈ ស្រុកស្រែអំបិល ខេត្តកោះកុង?

ធីៈ ចាំ!

ប៊ុនថនៈ សព្វថ្ងៃមីងរស់នៅភូមិឃុំអីដែរ?

ធីៈ ភូមិនេះ?

ប៊ុនថនៈ បាទ!

ធីៈ ភូមិប្រម៉ោយ ។

ប៊ុនថនៈ ឃុំ?

ធីៈ ឃុំប្រម៉ោយដែរ ។

ប៊ុនថនៈ ស្រុក?

ធីៈ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ប៊ុនថន: មីងមានបងប្អូនប៉ុន្មាននាក់?

ធីៈ បងប្អូនខ្ញុំពីដើមមាន៤នាក់ ។

ប៊ុនថន: ប្រុសប៉ុន្មានហើយ ហើយស្រីប៉ុន្មាន?

ធីៈ មានប្រុស២ ស្រី២ ប៉ុន្តែស្លាប់មួយហើយនៅតែ៣នាក់ទេរាល់ថ្ងៃ ។

ប៊ុនថន: ស្លាប់ជំនាន់ណាដែរ?

ធីៈ មិនដឹងជំនាន់ណា បើបែកគ្នាតាំងពីជំនាន់យើងប៉ុល ពត បងខ្ញុំគេធ្វើទ័ព ។

ប៊ុនថន: គាត់ចូលទ័ព?

ធីៈ ចា៎! គេចូលទ័ពតំបន់ ហើយខ្ញុំចូលខាងកុមារយោធា ដល់ពេលហើយបែករហូតទៅអត់ដែលបានជួបផង ប្រហែលជាស្លាប់ហើយ នៅតែបងខ្ញុំ២នាក់ហ្នឹង ។

ប៊ុនថន: គាត់នៅណាឥលូវ?

ធីៈ ឥលូវគាត់នៅស្រុក ។

ប៊ុនថន: នៅស្រែអំបិល?

ធីៈ ចា៎!

ប៊ុនថន: អ្នកមីងមានឪពុកម្តាយនៅរស់ទេ?

ធីៈ អត់មានផង គាត់ស្លាប់តាំងពីខ្ញុំនៅតូចៗ ។

ប៊ុនថន: ហើយអ្នកមីងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរកាលនៅក្មេងៗ?

ធីៈ រៀនបានថ្នាក់ទីប៉ុន្មានទេ ដូចជាអត់បានរៀនផង ។

ប៊ុនថន: ហើយថាមីងចូលកងអី?

ធីៈ ជំនាន់ខ្ញុំពីមុនហ្នឹង?

ប៊ុនថន: បាទ!

ធីៈ កាលពីមុននៅកុមារយោធា ដល់ក្រោយមកបានចូលកុមារសហករណ៍ តាមសហករណ៍ចូលនៅម្តុំវាលវិញព្រៃនុប ។

ប៊ុនថន: កាលហ្នឹងយើងស្ម័គ្រចិត្តចូលឬក៏គេរើសចូល?

ធីៈ អត់ទេ គេរំលាយចូលតាមសហករណ៍ហ្នង ព្រោះជំនាន់ខ្ញុំនៅកុមារយោធាអាហ្នឹងគេរើសយកទៅដាក់យោធា ដល់ពេលគេរំលាយយោធាអញ្ចឹងគេចែកតាមសហករណ៍ ។

ប៊ុនថន: កុមារយោធាហ្នឹងម៉េចវិញ?

ធី៖ កុមារយោធាដូចនៅក្នុងទ័ពអញ្ចឹង គេយកទៅរីករ៉ឺននៅកន្លែងទ័ព ដល់ពេលយើងស័គ្រចិត្ត ធ្វើទ័ពអញ្ចឹងទៅគេចូលធ្វើទ័ព ទៅវីគ្នា ។

ប៊ុនថន៖ អញ្ចឹងអ្នកមីងស័គ្រចិត្ត?

ធី៖ អត់ស័គ្រទេ កាលហ្នឹងគេរើសចំរាញ់យកអ្នកប្រវត្តិរូបល្អ ជំនាន់សម័យពន្លាំហ្នឹង គេយក យើងអត់មានជាប់ទិន្នាការអីហ្នឹង គេយកទៅ ដល់ហើយគេឲ្យចូលធ្វើទ័ពហ្នឹង ដល់ពេល ហើយអត់បាន គេអ្នកចូលមុនគេបានទៅវ៉ៃ ហើយពួកខ្ញុំនៅក្រោយអត់បានទៅក៏ចូលតាម សហករណ៍ទៅ ។

ប៊ុនថន៖ ប៉ុន្តែចូលដំបូងហ្នឹង អ្នកមីងនៅណា?

ធី៖ ខ្ញុំចូលដំបូងនៅស្រុកខ្ញុំនៅកោះកុង ប៉ុន្តែនៅម្តុំកំពង់សិលា ។

ប៊ុនថន៖ នៅម្តុំកំពង់សិលា?

ធី៖ ចា៎! ចុះពីភ្នំពិជនិលទៅ ។

ប៊ុនថន៖ ហើយខាងប្រមូលចូលហ្នឹងពីណា ដូចថាខាងអ្នកប្រមូល?

ធី៖ តាមឃុំ តាមភូមិ តាមស្រុកគេហ្នឹង ។

ប៊ុនថន៖ ហើយស្រីៗហ្នឹងអាចចូលយោធាបានដែរ?

ធី៖ ចូលបាន កុមារគេចូលទៅហាត់រីករ៉ឺន ដល់យើងអត់បាននេះអញ្ចឹងយើងចេញទៅ កាល ជំនាន់ហ្នឹងដូចថាមានគេចាប់មេក្បត់មេអីអញ្ចឹងទៅ ។ស

ប៊ុនថន៖ ហាត់អីខ្លះមីង ពេលដែលចូលទៅហ្នឹង?

ធី៖ មានហាត់អី មានតែហាត់យោធារបៀបថាបាញ់គ្នាអីហ្នឹង ជីករណ្តៅជីកអីដូចយើងធ្វើ សង្គ្រាម ។

ប៊ុនថន៖ បានហាត់បាញ់ទេមីង?

ធី៖ បានដែរហ្នឹង ។

ប៊ុនថន៖ បាញ់កាំភ្លើងពិតៗហ្នង?

ធី៖ បាញ់កាំភ្លើង បាញ់នេះអញ្ចឹងទៅ ។

ប៊ុនថន៖ មីងភ័យទេពេលដែលហាត់បាញ់ហ្នឹង?

ធី៖ អត់ភ័យផង សប្បាយ ។

ប៊ុនថន៖ សប្បាយ?

ធី៖ ចា៎! ព្រោះយើងនៅក្មេងវាចេះតែសប្បាយហើយ ។

ប៊ុនថន៖ ហើយបាញ់ត្រូវទេមីង?

ធីៈ មិនដែលត្រង់ទេ ព្រោះយើងបាញ់ម្តងៗ យើងបាញ់ម្នាក់មួយគ្រាប់ៗ មនុស្សវាច្រើន ។

ប៉ុនថនៈ ប៉ុន្មាននាក់ទៅ ។

ធីៈ រាប់ពាន់មនុស្ស ហាត់មែនតិចណា៎ ហាត់ច្រើនណាស់ ។

ប៉ុនថនៈ នៅកងរបស់មីងមានប្រុសៗទេ?

ធីៈ មាន មានកុមារាកុមារីពេញហ្នឹង ។

ប៉ុនថនៈ ភាគច្រើនអាយុប៉ុន្មានដល់ប៉ុន្មាន?

ធីៈ កាលជំនាន់ហ្នឹងច្រើនតែអាយុ កាលហ្នឹងធំៗដែរហ្នឹង ខ្វះគេ១៥-១៦ឆ្នាំហើយ គេរើស តាមតូចតាមធំ អ្នកណា១៥-១៦-១៧-១៨ហ្នឹងគេយកទៅមុខហើយ ។

ប៉ុនថនៈ យកទៅមុខហ្នឹងយកទៅណាវិញ?

ធីៈ មិនដឹងគេយកទៅណាផង អត់ដឹងផង ។

ប៉ុនថនៈ គេយកទៅវៃនៅមុខមែន?

ធីៈ ហ្នឹងហើយ កាលជំនាន់ហ្នឹងគេវៃថាទប់ទល់ជាមួយយួនហ្នឹង ហើយតូចៗចេះតែនៅហាត់ តទៅទៀតទៅ ។

ប៉ុនថនៈ ហាត់យូទេមីង?

ធីៈ អតទេ មួយថ្ងៃគេហាត់បានប៉ុន្មានម៉ោង ជំនាន់យើងនៅក្មេងៗហាត់ ។

ប៉ុនថនៈ ហើយក្រៅពីហាត់ហ្នឹងធ្វើអីទៀតទៅ?

ធីៈ ធ្វើស្រែ ហាត់ពេលព្រឹកអញ្ចឹងថ្ងៃត្រង់ ពេលគេមានពេលម៉ោងហាត់ ដូចថាក្នុងមួយអាទិត្យ អញ្ចឹងគេហាត់៣-៤ដងអញ្ចឹងទៅ គេមានពេលធ្វើការ ។

ប៉ុនថនៈ ហើយអ្នកណាអ្នកបង្ហាត់?

ធីៈ មេអង្គភាពគេ ។

ប៉ុនថនៈ គាត់នៅរស់ទេសព្វថ្ងៃ?

ធីៈ អត់ទេ គេចាប់វៃចោលអស់តាំងពីជំនាន់៣ឆ្នាំ ។

ប៉ុនថនៈ ចាំឈ្មោះគាត់ទេមីង?

ធីៈ ខ្ញុំចាំឈ្មោះតែមេកងខ្ញុំ ។

ប៉ុនថនៈ គាត់ឈ្មោះអី?

ធីៈ មេកងខ្ញុំនារីកុមារហ្នឹងឈ្មោះ បងសុខា ហើយបងថេន តែឥលូវមិនដឹងនៅណាទេបាត់អស់ ហើយ ប៉ុន្តែមេប្រធានកងធំ មេទ័ពគេហ្នឹងឈ្មោះ អ៊ុម តែគេវៃចោលអស់ហើយ ។

ប៉ុនថនៈ ឈ្មោះ អ៊ុម?

ធីៈ ចា៎! គេចាប់វ៉ៃចោលអស់ហើយ ។

ប៊ុនថនៈ អ៊ុំម ហ្នឹងគាត់អ្នកស្រុកណាដែរ?

ធីៈ អត់ស្គាល់ផង ។

ប៊ុនថនៈ អត់ស្គាល់ទេ?

ធីៈ ចា៎!

ប៊ុនថនៈ តែត្រកូលគាត់មីងស្គាល់ទេ?

ធីៈ អត់ដឹងដែរ ដឹងតែគាត់មេ ។

ប៊ុនថនៈ ចុះមីងដូចនៅហាត់ហ្នឹង ស្នាក់នៅយ៉ាងម៉េចដែរពេលគេឲ្យស្នាក់នៅ?

ធីៈ មានផ្ទះគេដែរហ្នឹង ផ្ទះកុមារាកុមារីគេដាក់ផ្សេងពីគ្នា គេសង់ផ្ទះឲ្យប៉ុនៗ ផ្ទះយើងធំៗដែរ កាលសម័យកសាងហ្នឹង ខ្ញុំហាត់នៅកំពង់សិលាសុទ្ធតែផ្ទះហ្នឹង នៅតាមផ្ទះគេ ធ្វើផ្ទះដូចផ្ទះ របបអញ្ចឹងណា៎ ធ្វើដាក់មួយផ្ទះហ្នឹងប៉ុន្មានក្រុមៗអញ្ចឹងទៅ ។

ប៊ុនថនៈ អត់ឲ្យនៅចូលគ្នាជាមួយប្រុសៗទេ?

ធីៈ អត់ទេ ប្រុសៗនៅឆ្ងាយពីគ្នា ដល់ពេលហាត់បានមកជួបគ្នា ។

ប៊ុនថនៈ ប៉ុន្តែអាចនិយាយគ្នាបានទេ?

ធីៈ បាន និយាយគ្នាបានធម្មតា មកហាត់រឹករ៉ឺន ហើយហាត់យោធាហ្នឹងហើយចូលក្រុមសិល្បះ អញ្ចឹងទៅលេងជាមួយគ្នាទៅ ។

ប៊ុនថនៈ អ្នកមីងបានចូលទេខាងសិល្បះហ្នឹង?

ធីៈ បានចូលតើ ខ្ញុំលេងសិល្បះ ។

ប៊ុនថនៈ សិល្បះហ្នឹងយើងមានផ្នែកអីខ្លះ?

ធីៈ អត់មានអីផង ពេលយើងមានរវល់ដូចថាបុណ្យទានអញ្ចឹងយើងគ្រាន់ហាត់ឡើងឆាកឡើងអី ទៅ ។

ប៊ុនថនៈ គេហាត់ពីអីខ្លះមីង?

ធីៈ ហាត់របបយើងច្រៀងជំនាន់៣ឆ្នាំហ្នឹង ។

ប៊ុនថនៈ ច្រៀង?

ធីៈ ចា៎! ហាត់ចំរៀងដូចជំនាន់យើងចាក់កាល៣ឆ្នាំអញ្ចឹង ។

ប៊ុនថនៈ ហាត់ច្រៀង ហើយមានហាត់ធ្វើកាយវិការដែរ?

ធីៈ ហាត់រាំហាត់អីទាំងអស់ហ្នឹង ។

ប៊ុនថនៈ ហើយមីងចេះទេរហូតដល់ថ្ងៃហ្នឹង?

ធី៖ ចេះតើ តែសម័យឥលូវអត់សូវចេះព្រោះវាគ្រាក់ទ្រើកហើយ ។

ប៊ុនថន៖ បទអីខ្លះមឹងកាលសម័យហ្នឹង?

ធី៖ កាលសម័យហ្នឹងរាំវង់ ។

ប៊ុនថន៖ មីងនៅចាំទេ?

ធី៖ ចាំដែរហ្នឹង តែយើងឥលូវគេមិនរាំទេសម័យ៣ឆ្នាំហ្នឹង ។

ប៊ុនថន៖ បទយើងខ្ញុំកុមារអីមានទេ?

ធី៖ មាន ឲ្យតែជំនាន់៣ឆ្នាំយើងហាត់តែអាហ្នឹង ។ ។

ប៊ុនថន៖ មីងអាចនៅចាំ ច្រៀងបន្តិចបានទេ?

ធី៖ ភ្លេចអស់ហើយ ព្រោះអត់ដែលរំលឹកអារឿងច្រៀងហ្នឹងផង បើមានចម្រៀងចេះតែចាក់ចេះតែចាំហើយ ឥលូវមិនដែលមានផង ។

ប៊ុនថន៖ អញ្ចឹងខាងហាត់សិល្បះហ្នឹងផ្សេងទៀត មានគ្រូផ្សេងទៀត?

ធី៖ ផ្សេង មានគ្រូផ្សេង ។

ប៊ុនថន៖ គេហាត់ទាំងអស់គ្នា ឬមួយគេជ្រើសរើស?

ធី៖ អត់ទេ គេជ្រើសរើស ។

ប៊ុនថន៖ គេជ្រើសរើសយ៉ាងម៉េចទៅ?

ធី៖ ជ្រើសរើសដូចថាអ្នកណាស័គ្រចិត្តចូលសិល្បះគេយក អ្នកណាអត់ចូលអត់ ប៉ុន្តែក្នុងមួយក្រុមគេរើសតែប៉ុន្មាននាក់ទេ យកអត់ច្រើនផង ។

ប៊ុនថន៖ គេអត់មានប្រលងមានអីទេ?

ធី៖ អត់ប្រលងទេ គ្រាន់តែគេរើសអ្នកពូកែៗ ដូចខាងយើងសិល្បះគេទុកមួយខាង សិល្បះអញ្ចឹងទៅ គេមិនសូវធ្វើបាបអីទេអ្នកខាងសិល្បះ ប៉ុន្តែសម័យហ្នឹងខ្ញុំមិនសូវពិបាកទេ មានអ្នកធំគេជួយយកមកនៅជាមួយគេ ពិបាកខ្លះដែរ ។

ប៊ុនថន៖ អ្នកធំហ្នឹងពីណាគេ?

ធី៖ អ្នកធំដូចខាងចៅហ្វាយស្រុកអញ្ចឹងទៅ គេស្គាល់ខាងបងប្អូនយើងធ្លាប់ធ្វើការជាមួយគេអញ្ចឹង គេដឹងទុរៈខ្សែអញ្ចឹងគេយកមកនៅជាមួយ ។

ប៊ុនថន៖ គាត់ឈ្មោះអីចៅហ្វាយស្រុកហ្នឹង មីងមាននៅចាំទេ?

ធី៖ ចៅហ្វាយស្រុកកាលហ្នឹង អ៊ឹជល ខ្ញុំនេះពូ ជល យើងបរិស្ថានពីមុនហ្នឹង កាលជំនាន់ហ្នឹងគាត់នៅចៅហ្វាយស្រុកនៅនោះ ។

ប៊ុនថន៖ គាត់ចៅហ្វាយស្រុកនៅណា?

ធី៖ ស្រុកព្រៃនុប ។

ប៊ុនថន៖ មឹងមានបានសម្តែងទេ កាលហាត់សិល្បៈ?

ធី៖ សម្តែងអីគេ?

ប៊ុនថន៖ បានឡើងសម្តែងទេមឹង?

ធី៖ បាន ។

ប៊ុនថន៖ ច្រើនដងទេ?

ធី៖ ឡើងគ្រប់ឆាកដែរហ្នឹង ឲ្យតែមានវេលបុណ្យទានអីឡើងរាំលើឆាក ខ្ញុំរាំមនុស្សច្រើនណាស់ មនុស្សរាប់ពាន់មនុស្ស ។

ប៊ុនថន៖ សម្តែងនៅក្នុងកម្មវិធីអីខ្លះមឹង?

ធី៖ មានអី មានតែចេញរាំក្បាច់យើងធម្មតា យើងរាំបទអីៗអញ្ចឹងណា៎ រាំតាមហ្នឹងទៅ អត់ដែលលេងល្ខោនលេងអីផង គ្រាន់តែសិល្បៈធម្មតា ។

ប៊ុនថន៖ ហើយសម្តែងហ្នឹងនៅក្នុងកម្មវិធីអី?

ធី៖ កម្មវិធីដូចថាគេមានវេលបុណ្យអីៗ មនុស្សធំៗមកលេងអញ្ចឹងណា៎ ។

ប៊ុនថន៖ ចុះមានគណៈធិបតេយ្យមកមើលទេ?

ធី៖ គេមកមើលអញ្ចឹងសិល្បៈយើងលេងសម្តែងឲ្យគេមើលទៅ ឡើងឆាកឡើងអីទៅ ។

ប៊ុនថន៖ មានចាំឈ្មោះអ្នកដែលមកមើលទេ?

ធី៖ អត់ដែលស្គាល់គេទេ ។

ប៊ុនថន៖ អ្នកធំៗដែរ?

ធី៖ ចា៎!

ប៊ុនថន៖ ចុះមានសម្តែងឲ្យកងទ័ពមើលទេមឹង?

ធី៖ ដែល គេធ្វើបុណ្យអញ្ចឹងដូចថា គេធ្វើបុណ្យអីរួមគ្នាអញ្ចឹងមានទ័ពមានអីមកអញ្ចឹង អញ្ចឹងពួកក្រុមសិល្បៈគេឡើងមកសម្តែង មុននឹងគេដូចថាគេធ្វើបុណ្យធំអីមួយអញ្ចឹង ពួកខ្ញុំកំពង់លើកទំនប់ប្រឡាយហ្នឹងគេប្រមូលមកហើយ មួយក្រុមសិល្បៈហ្នឹងគេយកមកហាត់៣-៤ថ្ងៃមុនអញ្ចឹងទៅ ហាត់ឲ្យយើងចាំចេះដើរទៅណាទៅណីអញ្ចឹងទៅ ហើយយើងហាត់រាំបទអីៗអញ្ចឹង ដល់ពេលដល់ថ្ងៃគេបុណ្យហ្នឹងយើងទៅហាត់ទៅរាំលើឆាកហ្នឹង មិនមែនតែក្រុមសិល្បៈហ្នឹងអត់ធ្វើការងារទេ ធ្វើតែទាំងអស់ហ្នឹង ដូចថាពេលឥលូវដល់ថ្ងៃបុណ្យអញ្ចឹងគេយកយើងមួយអាទិត្យមុនយកមកហាត់សិន ។

ប៊ុនថន៖ អញ្ចឹងទៅធ្វើស្រែមិនខ្មៅអស់ហើយមឹង?

ធី៖ ចុះមានអី ខ្មៅៗទៅ ដល់ពេលយើងត្រូវភ្ជើងភ្លើវិញហើយ ។

ប៊ុនថន៖ អញ្ចឹងសម្ដែងពេលយប់ឬក៏ពេលថ្ងៃ?

ធី៖ ពេលយប់ រាំតែពេលយប់ទេ មិនដែលរាំពេលថ្ងៃទេ ។

ប៊ុនថន៖ ហើយចេញទៅសម្ដែងនៅណាខ្លះមីង?

ធី៖ សម្ដែងតែតាមស្រុកហ្នឹង តាមស្រុកតាមភូមិ ។

ប៊ុនថន៖ ស្រុកណាខ្លះមីង?

ធី៖ នៅស្រុកព្រៃនុបហ្នឹង រាំតែនៅស្រុកហ្នឹង អត់ដែលទៅលេងណាទេ ។

ប៊ុនថន៖ អាហ្នឹងគេហៅសិល្បៈអីវិញមីង?

ធី៖ សិល្បៈតាមសហករណ៍គេ ។

ប៊ុនថន៖ សិល្បៈសហករណ៍?

ធី៖ចាំ!

ប៊ុនថន៖ ហើយអ្នកណាអ្នកដឹកនាំ?

ធី៖ មេៗគេ មេអង្គភាពគេ ។

ប៊ុនថន៖ ឈ្មោះអីខ្លះ?

ធី៖ មេកងខ្ញុំ បងសុខា ហ្នឹង ។

ប៊ុនថន៖ អត់ដែលឡើងទៅសម្ដែងនៅខេត្តផ្សេងៗទេ?

ធី៖ អត់ដែលទេ លេងតែនៅក្នុងស្រុកហ្នឹង សិល្បៈតាមភូមិគេហ្នឹង ដូចថាគេអត់យកមកពីណាឆ្ងាយអញ្ចឹង ប៉ុន្តែជំនាន់ហ្នឹងគេប្រមូលតែមួយភូមិស្រុកហ្នឹងគេលេងតែមួយភូមិស្រុកហ្នឹង គេអត់យកទៅលេងណាទៀតទេ កាលជំនាន់ពាឆ្នាំគេបង្កើតតែប៉ុណ្ណឹង អត់មានយកទៅលេងណាទេ អត់ដែលយកទៅលេងប្រលងណាផង មានបានសូត្រណា បើកុំតែយួនចូលអញ្ចឹងបែបបានប្រលងខាងណាខាងណី ដល់ពេលយួនចូលអញ្ចឹងចប់ហើយ ដាច់រត់អាគាត់អាគាយអស់ បែកខ្ញែកគ្នាអស់ ។

ប៊ុនថន៖ ចុះដូចសម្ដែងម្ដងៗអញ្ចឹង គេមានឲ្យមានប្រជាជនមើលទេ?

ធី៖ គេឲ្យមើល ប្រជាជនមកពេញហ្នឹង ប៉ុន្តែខ្ញុំអត់សូវសម្ដែងបានច្រើនទេ ខ្ញុំគ្រាន់តែបានឡើងឆាកប្រហែល១០ដងដែរ ដល់ពេលហើយក្រោយមកខ្ញុំឈប់នៅកន្លែងកុមារហ្នឹងខ្ញុំមកនៅកន្លែងមន្ទីរស្រុកវិញ ឈប់បានចូលកុមាររាំហ្នឹងទៅ ។

ប៊ុនថន៖ គេជ្រើសរើសមីងចេញពីហ្នឹងឬក៏មីងសុំគេដូរ?

ធី៖ អត់សុំផង គាត់ទៅយក ។

ប៊ុនថន៖ ពីណាគេទៅយក?

ធី៖ ចៅហ្វាយស្រុកហ្នឹង គាត់ទៅយកខ្ញុំពីកន្លែងកុមារហ្នឹងមក មកនៅកន្លែងគាត់ ។

ប៊ុនថន៖ ចៅហ្វាយស្រុកដែលថាឈ្មោះ ផល ហ្នឹងមែន?

ធី៖ ចា៎!

ប៊ុនថន៖ ហ្នឹងត្រូវជាអីហ្នឹងមីង?

ធី៖ អត់ត្រូវអីផង ។

ប៊ុនថន៖ តែគាត់ស្គាល់?

ធី៖ គាត់ស្គាល់បងខ្ញុំ គេធ្លាប់ធ្វើការជាមួយគ្នា បងស្រីខ្ញុំកាលជំនាន់៣ឆ្នាំហ្នឹងគាត់ធ្វើប្រធានសហករណ៍ ហើយគេធ្វើការជាមួយគ្នាអញ្ចឹងទៅ ដល់ហើយគេស្គាល់តាមរយៈហ្នឹង គាត់ប្រាប់ថាប្អូនស្រីគាត់នៅធ្វើសហករណ៍នៅហ្នឹងអញ្ចឹង គាត់ស្រាវជ្រាវតាមហ្នឹងទៅយកខ្ញុំមក ។

ប៊ុនថន៖ ឈ្មោះ ផល អ្នកទៅយកមីង?

ធី៖ ចា៎!

ប៊ុនថន៖ មីងមកខាងស្រុកព្រៃនុប?

ធី៖ ខ្ញុំនៅស្រែអំបិលទេ ប៉ុន្តែខ្ញុំចូលកុមារយោធាខ្ញុំចូលនៅម្តុំកំពង់សិលា ដល់ពេលគេរំលាយកុមារហ្នឹងទៅគេបញ្ជូលទៅខាងស្រុកព្រៃនុប ។

ប៊ុនថន៖ អញ្ចឹងមកនៅខាងស្រុកជាមួយពូ ផល?

ធី៖ ចា៎!

ប៊ុនថន៖ កាលហ្នឹងគេហៅស្រុកព្រៃនុបហ្នឹង ឬមួយគេហៅស្រុកអីផ្សេងទៀត?

ធី៖ គេហៅស្រុកព្រៃនុប ។

ប៊ុនថន៖ មីងនៅតំបន់ប៉ុន្មាន?

ធី៖ កាលជំនាន់ហ្នឹងគេហៅតំបន់៣៧ ។

ប៊ុនថន៖ តំបន់៣៧នៅព្រៃនុបហ្នឹង?

ធី៖ អត់ទេ កោះកុងហ្នឹងរួមគ្នាតំបន់៣៧ ។

ប៊ុនថន៖ ហើយពីណាគេគណៈតំបន់កាលហ្នឹង?

ធី៖ កាលហ្នឹងគណៈតំបន់ពីដំបូងឈ្មោះ សឿង ។

ប៊ុនថន៖ ឈ្មោះអី សឿង?

ធី៖ ខ្ញុំអត់ស្គាល់ទេ តែពួកគេហៅ សឿន១ ដល់ពេលក្រោយមកគាត់ផ្លាស់ចេញ ខ្ញុំពីមុនមកខ្ញុំមិនដឹងពីណាទេ ដឹងមកដឹងត្រឹមអ៊ំ សឿន ពីមុន១មកខ្ញុំអត់ដឹងទេ ហើយអ៊ំ សឿន ហ្នឹងក៏ខ្ញុំអត់ដឹងដែរ ដល់ក្រោយមកបានអ៊ំ សឿន ផ្លាស់ទៅបានចូលមកគឺពូ ផល ចៅហ្វាយស្រុកដែលខ្ញុំនៅជាមួយហ្នឹង គាត់ចូលមកតំបន់ហ្នឹងវិញ ហើយខ្ញុំមកតាមគាត់នៅតំបន់ហ្នឹងវិញ ។

ប៊ុនថន៖ អញ្ចឹងពូ ផល ហ្នឹងគាត់ឡើងតំបន់ដែរ?

ធី៖ គាត់ឡើងតំបន់ដែរ ដល់ពេលគាត់ឡើងតំបន់គាត់មកនៅស្រែអំបិលដែរ មកជិតស្រុកខ្ញុំវិញហ្នឹង ដល់ពេលហើយខ្ញុំមកហ្នឹងវិញមក ។

ប៊ុនថន៖ ចុះពូ ផល ហ្នឹងគាត់នៅរស់ទេសព្វថ្ងៃ?

ធី៖ នៅរស់តើ ។

ប៊ុនថន៖ គាត់នៅណាវិញសព្វថ្ងៃ?

ធី៖ គាត់នៅ៨០

ប៊ុនថន៖ ៨០ហ្នឹងនៅណា?

ធី៖ ៨០ហ្នឹងនៅអន្លង់រាប ។

ប៊ុនថន៖ នៅអន្លង់រាប?

ធី៖ ចាំ! គាត់នៅដីក្រហម កាលមុននៅធ្វើការបរិស្ថាននេះ ។

ប៊ុនថន៖ នៅភូមិអន្លង់រាប?

ធី៖ ចាំ!

ប៊ុនថន៖ យើងទៅដល់ទេមីង?

ធី៖ ដល់ ។

ប៊ុនថន៖ ប្រហែលជាប៉ុន្មានគីឡូពីហ្នឹងទៅ?

ធី៖ មិនដឹងប៉ុន្មានគីឡូផង ។

ប៊ុនថន៖ គាត់គណៈតំបន់ដែរ?

ធី៖ ចាំ!

ប៊ុនថន៖ ឈ្មោះអី ផល?

ធី៖ ខ្ញុំអត់ដឹងទេ ខ្ញុំអត់ដឹងត្រកូលគាត់ផង ។

ប៊ុនថន៖ ប៉ុន្តែមុំហ្នឹងសួរគេ គេស្គាល់ទេមីង?

ធី៖ ស្គាល់តើ ។

ប៊ុនថនៈ គាត់គណៈតំបន់៣៧ហ្នឹងហ្នុង?

ធីៈ ចាំ!

ប៊ុនថនៈ ហើយមីងទៅនៅជាមួយគាត់ហ្នឹងធ្វើអីខ្លះ?

ធីៈ អត់មានធ្វើអីផង នៅចាំផ្ទះគាត់ គាត់អត់មានក្មេងនៅចាំផ្ទះហើយកាលហ្នឹងខ្ញុំនៅតូចៗ ខ្ញុំស្គាល់ជាមួយអ៊ំ យ៉ន់ តាំងពីជំនាន់៣ឆ្នាំ ។

ប៊ុនថនៈ អ៊ំ យ៉ន់ កាលហ្នឹងគាត់ធ្វើអី?

ធីៈ គាត់ខាងយោធា ។

ប៊ុនថនៈ ខ្ញុំជួបគាត់ដែរ ។

ធីៈ គាត់នៅខាងយោធា ខ្ញុំជួបគាត់កាលសម័យ ស្គាល់តាំងពីសម័យ៣ឆ្នាំជាមួយគ្នាហ្នឹង ប៉ុន្តែខ្ញុំនៅតូចគាត់ចាស់ ។

ប៊ុនថនៈ កាលហ្នឹងពូ ផល ហ្នឹងគាត់មានគ្រួសារហើយនូវ?

ធីៈ កាលសម័យហ្នឹងគាត់មានដែរហ្នឹង គ្រួសារគាត់ស្លាប់កាលជំនាន់វត់យួន

ប៊ុនថនៈ កាលហ្នឹងគាត់មានកូនទេ?

ធីៈ កាលសម័យហ្នឹងគាត់មានកូនតូចមួយ តែស្លាប់តាំងអស់ហើយ ឥលូវគាត់យកប្រពន្ធទៀតស្លាប់តាំងសម័យវត់យួន ។

ប៊ុនថនៈ អញ្ចឹងអ្នកមីង ក្រៅពីនៅមើលផ្ទះគាត់ហ្នឹងមានធ្វើអីទៀតទេ?

ធីៈ ធ្វើការក្នុងផ្ទះហ្នឹង ដាំបាយដាំអីហ្នឹងអត់មានធ្វើអីផង ។

ប៊ុនថនៈ ហើយមានភ្ញៀវមានអីមកលេងទេ?

ធីៈ បើខ្ញុំមកនៅកន្លែងតំបន់បានមានភ្ញៀវ ភ្ញៀវគេចូលមកធ្វើការធ្វើអី អ្នកស្រុកអ្នកឃុំអញ្ចឹងណាំ មេឃុំអីគេមក ហើយពួកខ្ញុំនៅតូចៗដាំបាយដាំអីទទួលភ្ញៀវទៅ ។

ប៊ុនថនៈ ច្រើនគ្នាទេអ្នកមីង?

ធីៈ ច្រើនដែរហ្នឹង ។

ប៊ុនថនៈ ប្រហែលប៉ុន្មាន?

ធីៈ ពួកខ្ញុំប្រហែលជា១ក្រុមនៅហ្នឹង ។

ប៊ុនថនៈ ហ្នឹងគេអត់មានដាក់ឈ្មោះក្រុមអីទេ?

ធីៈ អត់មានក្រុមអីផង គ្រាន់តែនៅជាមួយគ្នាទាំងអស់គ្នា មានអ្នកធំ មានគេធំៗជាងខ្ញុំ៣-៤នាក់អញ្ចឹងទៅ ដាំបាយដាំអីគេប្រើយើងអ្នកតូចៗអញ្ចឹងណាំ ។

ប៊ុនថនៈ មីងនៅផ្ទះគាត់ហ្នឹងរយៈពេលប៉ុន្មានបានដូរមកតំបន់វិញ?

ធី:	អត់ទេ ខ្ញុំនៅតំបន់ហ្នឹងតើ រត់ឃ្លួនហ្នឹងបែកគ្នាហ្នឹង ។

ប៊ុនថន:	ហើយមីងថានៅជាំបាយផ្ទះគាត់ហ្នឹង?

ធី:	នៅស្រុកហ្នឹងមែន?

ប៊ុនថន:	បាទ! នៅស្រុកហ្នឹង?

ធី:	នៅប្រហែលជា១ឆ្នាំ ដល់ហើយគាត់ឡើងមកតំបន់ខ្ញុំមកតំបន់វិញ ។

ប៊ុនថន:	ចុះអ្នកចាស់ហ្នឹងផ្លាស់ទៅណាវិញ?

ធី:	អ្នកចាស់ហ្នឹងគេថាយកទៅភូមិភាគណា ដល់ពេលយកទៅឮដំណឹងថាស្លាប់ទៅ មិនដឹងម៉េច កាលជំនាន់ហ្នឹងអង្គការផ្លាស់លិចផ្លាស់កើត ខ្ញុំដឹងគេយកទៅណាផង ។

ប៊ុនថន:	អញ្ចឹងនៅគាត់?

ធី:	ចា៎!

ប៊ុនថន:	ពេលគាត់មកតំបន់គ្រួសារគាត់មកនៅតំបន់ទាំងអស់មែន?

ធី:	នៅហ្នឹង គ្រួសារគាត់នៅខាងពេទ្យ គាត់អត់សូវនៅជួបជុំគ្នាផងគាត់នៅតែពេទ្យ ដល់ពេល យប់បានគាត់មកលេងដេកជាមួយប្ដីរបស់គាត់ ពេលថ្ងៃគាត់ទៅធ្វើការ ។

ប៊ុនថន:	គេហៅពេទ្យអីវិញមីង?

ធី:	ពេទ្យតំបន់៣៧ ។

ប៊ុនថន:	កាលហ្នឹងតំបន់៣៧មានស្រុកអីខ្លះ មីងចាំទេ?

ធី:	មិនដឹងមានស្រុកអីខ្លះទេ មានស្រុកថ្មស ថ្មបាំង ស្រែអំបិល ហើយនឹងស្អីខ្លះទេខ្ញុំភ្លេចអស់ ហើយ ខ្ញុំមិនដឹងដែរ ខ្ញុំមិនសូវចេះចាំនឹងគេផង ។

ប៊ុនថន:	នៅកោះកុងហ្នឹងគាត់ក្ដោបទាំងអស់មែនមីង?

ធី:	ចា៎!

ប៊ុនថន:	ចុះនៅខាងតំបន់ហ្នឹង ក្រៅវដែលទៅហ្នឹងមីងមាននៅចាំឈ្មោះទេ?

ធី:	អត់ចាំទេ អត់ស្គាល់ផង ព្រោះនៅតូចៗដែរ ។

ប៊ុនថន:	ចុះពីលើគាត់ហ្នឹងមានអ្នកទៅទេមីង ពីលើ ពូផល ហ្នឹងអ្នកធំ?

ធី:	មានដែរហ្នឹង វាមិនអត់ទេ ។

ប៊ុនថន:	ពីណាខ្លះ?

ធី:	ខ្ញុំអត់ស្គាល់ផង មិនដែលចាំឈ្មោះគេទេ ។

ប៊ុនថន:	ចុះខាងភូមិភាគមីងដឹងទេមីង ខាងលើគាត់?

ធី:	អត់ អត់ដឹងផង ។

ប៊ុនថន៖ ដូ ចេត អីមានដែលចាំទេមីង ដូ ចេត ហៅតាស៊ី?

ធី៖ អត់ស្គាល់ផង ។

ប៊ុនថន៖ សែ អីមីងអត់ស្គាល់ទេ?

ធី៖ ខ្ញុំអត់ស្គាល់ទេ ។

ប៊ុនថន៖ ស្គាល់តែ ពូផល?

ធី៖ ស្គាល់តែអ្នកធ្លាប់នៅជាមួយ ដូចប៉ុល ពត ខ្ញុំណា៎ដែលស្គាល់ ស្គាល់តែតាមទូរទស្សន៍ ខៀវ សំផន អីហ្នឹងខ្ញុំមិនដែលស្គាល់ទេ ស្គាល់តែតាមទូរទស្សន៍ ។

ប៊ុនថន៖ អញ្ចឹងគណៈតំបន់ដូចគ្នាដែលស្គាល់ទេមីង គណៈតំបន់ដែលនៅជិតៗហ្នឹងដែរ ដូច ពូផល?

ធី៖ គណៈតំបន់ជិតហ្នឹងស្គាល់ដែរ ស្គាល់អ្នកតំបន់រងគាត់ហ្នឹងមាន តាស៊ុំ តែគាត់ស្លាប់ហើយ ។

ប៊ុនថន៖ រងគាត់ពូស៊ុំ?

ធី៖ ចា៎!

ប៊ុនថន៖ មានពីណាទៀតមីង?

ធី៖ អត់ដឹងមានពីណាទៀតទេ ខ្ញុំភ្លេចអស់ហើយ ស្គាល់ច្បាស់ជាងគេមានតែ ពូស៊ុំ ហើយនឹង ពូផល គាត់ធ្លាប់អាសារមកផ្ទះរបស់ខ្ញុំ ។

ប៊ុនថន៖ នៅកន្លែងនោះមានខាងអ្នកធំៗចុះទៅមើលទេមីង?

ធី៖ មានដែរហ្នឹង ប៉ុន្តែខ្ញុំមិនសូវចាប់អារម្មណ៍ ហើយណាមួយគេអ្នកធំផងគេមកធ្វើការងារគេ យើងនៅផ្ទះយើង កន្លែងដាំបាយដាំអីមិនសូវចាប់អារម្មណ៍ទេ ដូចថាយើងអត់មានការងារ អីទៅជិតគេ ។

ប៊ុនថន៖ អញ្ចឹងមីងអត់មានបានដើរទៅណាផ្សេងទេ នៅតែតំបន់ហ្នឹង?

ធី៖ ចា៎! អត់ដែលទៅណាផង ។

ប៊ុនថន៖ កាលហ្នឹងតំបន់គេនៅម្ដុំណាវិញ?

ធី៖ នៅវត្តហ្នឹងហ្នង នៅវត្តស្រែអំបិលហ្នឹង ។

ប៊ុនថន៖ វត្តស្រែអំបិល?

ធី៖ ចា៎! ឥលូវគេធ្វើផ្សារអស់ហើយ ។

ប៊ុនថន៖ នៅក្នុងបរិវេនវត្តហ្នឹងហ្នង?

ធី៖ ចា៎! នៅក្នុងវត្តហ្នឹង ។

ប៊ុនថន៖ ហើយមីងស្នាក់នៅហ្នឹងហ្នង?

ធី៖ ចា៎!

ប៊ុនថន: ហើយ ពូផល នៅហ្នឹងដែរ?

ធី: នៅហ្នឹង តែផ្ទះគាត់ផ្សេង ហើយផ្ទះពួកខ្ញុំផ្សេង ហើយផ្ទះភ្ញៀវសម្រាប់មកស្នាក់ហ្នឹងផ្សេង ធ្វើផ្ទះពីរបីដំណាក់សម្រាប់ភ្ញៀវមកធ្វើការអីគេនៅស្នាក់ហ្នឹង ដូចតែកន្លែងភ្ញៀវទៅអស់យើងនៅបោសផ្ទះដូចផ្ទះសំណាក់អញ្ចឹង គេរៀបមកអញ្ចឹងយើងរៀបចំកន្លែងឲ្យគេ បោសកន្លែងបោសអីរៀបចំឲ្យគេ គេស្នាក់ប៉ុន្មានថ្ងៃៗអញ្ចឹងគេទៅអស់យើងចាប់ផ្ដើមប្រមូលដូចកូនឈ្នួលគេអញ្ចឹង ។

ប៊ុនថន: អាសារមកទេមីង?

ធី: មករាល់ថ្ងៃ មកញឹកសឹងអី ចុះគេត្រូវកាប្រជុំត្រូវការអី អញ្ចឹងគេមកជួបជុំគ្នាហ្នឹង ។

ប៊ុនថន: ហើយមីងក្រៅពីការងារហ្នឹងមានធ្វើអីទៀតទេ ក្រៅពីការងារបោសរៀបចំបាយទឹក?

ធី: អត់មានធ្វើអីផង ។

ប៊ុនថន: អត់មានទៅធ្វើស្រែទៀតទេ?

ធី: អត់ទេ នៅកន្លែងមន្ទីរហ្នឹងខ្ញុំឈប់ធ្វើស្រែហើយ ។

ប៊ុនថន: អញ្ចឹង ពូផល ហ្នឹងគាត់រវល់ទេមីង ដូចថាការងារអី?

ធី: អត់ដែលនៅផ្ទះផង មិនដឹងគាត់ទៅធ្វើការខាងណា ពេលមានភ្ញៀវមកប្រជុំនៅហ្នឹង រៀនសូត្រនៅហ្នឹងបានគាត់មកផ្ទះ មិនដឹងគាត់ចុះទៅធ្វើការខាងអីៗខ្ញុំអត់ដឹងដែរ ។

ប៊ុនថន: អញ្ចឹងយប់ៗគាត់មកវិញឬក៏គាត់ទៅបាត់២-៣ថ្ងៃអី?

ធី: គាត់ទៅមួយភ្លែតៗ មួយម៉ោងពីរម៉ោងអីគាត់មកកន្លែងវិញ គេធ្វើការអត់ចោលផ្ទះផង មិនដឹងគាត់ធ្វើការខាងអីទេ ។

ប៊ុនថន: ចុះដូចថាគាត់ដែលនិយាយរឿងការងារអីប្រាប់មីងទេ ដូចថាធ្វើការងារអញ្ចេះអញ្ចុះ?

ធី: អត់ដែលទេ ព្រោះយើងតូចៗគាត់និយាយប្រាប់ធ្វើអី ។

ប៊ុនថន: គាត់កាលហ្នឹងអាយុប៉ុន្មានហើយ គាត់ចំណាស់ណាំ?

ធី: គាត់ចាស់ដែរ គាត់ធ្វើការហ្នឹងចាស់ដែរ អាចប្រហែលជាខ្ទង់សែខ្ទង់ហាដែរហ្នឹង កាលនៅហ្នឹង ។

ប៊ុនថន: មកដល់ឥលូវប្រហែលជាប៉ុន្មាន?

ធី: មិនដឹងប៉ុន្មានទេ អាយុគាត់ប្រហែលជា៦០-៧០ហើយ ។

ប៊ុនថន: ចុះការងារហ្នឹងពិបាកទេមីង ក៏អត់សូវពិបាក?

ធី: ពិបាកដែរ តែពិបាកតែអ្នកដែលធ្វើស្រែធ្វើអីហ្នឹង ។

ប៊ុនថន: ចុះមីងនៅខាងតំបន់?

ធី៖ ខ្ញុំបើតាមបុគ្គលខ្ញុំអត់សូវពិបាកប៉ុន្មានទេ ប៉ុន្តែអ្នកខ្លះគ្នាពិបាកដែរ ពិបាកដូចថាគេប្រើអត់សូវទៀងទាត់ ប្រើហើយឲ្យបាយហូបអត់ឆ្អែតទៀត ប៉ុន្តែខ្ញុំអត់សូវពិបាកប៉ុន្មានទេ ។

ប៊ុនថន៖ នៅខាងតំបន់?

ធី៖ ចា៎!

ប៊ុនថន៖ អញ្ចឹងមីងនៅជាមួយ ពូផល ហ្នឹងរហូតឬក៏ដូរទៅណាទៀត?

ធី៖ ខ្ញុំនៅរហូតទាល់តែយួនចូលហ្នឹងបានខ្ញុំបែកពីគាត់ ខ្ញុំបែកហ្នឹងបែករហូតទល់សព្វថ្ងៃ ដល់ពេលទើបតែជួបគាត់វិញ ។

ប៊ុនថន៖ គាត់នៅស្គាល់ទេ?

ធី៖ ស្គាល់តើ គ្រាន់ជួបស្គាល់ ខ្ញុំបែក៧៩ហ្នឹងរត់ៗទៅជួបគាត់នៅទន្លេវិញ ទៅនៅទន្លេសាបជាមួយគាត់វិញ ។

ប៊ុនថន៖ ទន្លេសាប?

ធី៖ ចា៎!

ប៊ុនថន៖ ទៅខាងណាវិញ ទន្លេសាបហ្នឹង ។

ធី៖ ទន្លេសាបចុះទៅខាងកំពង់ឆ្នាំង ខាងកំពង់លែង ។

ប៊ុនថន៖ ទៅខាងកំពង់លែង?

ធី៖ ចា៎!

ប៊ុនថន៖ កាលហ្នឹងគាត់ទៅធ្វើអីមីង?

ធី៖ កាលជំនាន់ហ្នឹងជំនាន់យួនចូលហ្នឹង មិនដឹងគេយកគាត់ទៅធ្វើអីខ្ញុំអត់ដឹងដែរ ដល់ហើយយួនចូលហ្នឹងខ្ញុំចេះតែរត់ៗ ដល់ពេលរត់ទៅឮដំណឹងថាគាត់នៅកំពង់ឆ្នាំងនៅទន្លេហ្នឹង ហើយពួកខ្ញុំចេះតែរត់ៗទៅជួប ជួបគាត់ទៅនៅទន្លេហ្នឹង ។

ប៊ុនថន៖ មីងទៅនៅជាមួយគាត់ទៀតមែន?

ធី៖ ចា៎! នៅជាមួយគាត់ទៀត ។

ប៊ុនថន៖ ហ្នឹងគាត់តួនាទីអីដែរកាលហ្នឹង?

ធី៖ កាលហ្នឹងគាត់អត់មានធ្វើតួនាទីអីទេ គាត់ទៅនៅធ្វើទ័ព ។

ប៊ុនថន៖ ធ្វើទ័ព?

ធី៖ ហ្នឹងហើយ ធ្វើកងទ័ព នៅជាមួយទ័ពហ្នឹង ។

ប៊ុនថន៖ ហើយមានដឹងថាគាត់កងវរៈប៉ុន្មានទេ?

ធី៖ ខ្ញុំអត់ដឹងផង ដល់ពេលនៅជាមួយគាត់ហ្នឹងហើយជិត៨១ហ្នឹង ខ្ញុំឡើងមកព្រំដែនថៃចោលគាត់ទៅ គាត់ឡើងទៅមួយពាន់បីវិញ ទៅខាងនោះវិញ ។

ប៊ុនថន៖ មួយពាន់បីហ្នឹងខាងណា ទៅខាងព្រះវិហារមែន?

ធី៖ ទៅម្តុំសៀមរាបអីហ្នឹង គាត់ឡើងទៅហ្នឹង ហើយខ្ញុំឡើងមកខាងកោះកុងវិញ ។

ប៊ុនថន៖ ម៉េចបានជាមីងមកម្នាង ហើយគាត់បែកទៅម្នាង?

ធី៖ កាលហ្នឹងគេឲ្យនារីមកព្រំដែន ទុកនោះខ្លាចពិបាកពេក ខ្លាចយួនចាប់ខ្លាចអីហ្នឹង អង្គការគេមានរយៈនៅនេះគេពួកខ្ញុំមកនេះមក ។

ប៊ុនថន៖ គេចាំទទួល?

ធី៖ គេចាំទទួល មកនៅដឹកជញ្ជូនជាមួយគេនេះមក ។

ប៊ុនថន៖ ច្រើនគ្នាទេមីងកាលមកហ្នឹង?

ធី៖ ច្រើនរាប់រយ ។

ប៊ុនថន៖ ហើយ ពូផល គាត់ទៅទន្លេសាបហ្នឹងគាត់មានកាន់ទាហាន កាន់កូនទាហានអីទេ?

ធី៖ កាន់ទ័ពគាត់ ដល់ពេលគាត់ឡើងទៅខាងជើងហ្នឹងទៅ ឡើងទៅហ្នឹងដល់គេប្រមូលមកជួយវៃខាងនេះគាត់មកខាងនេះវិញ ដល់ពេលមកជួបខ្ញុំនៅនេះទៀត ។

ប៊ុនថន៖ គាត់កាន់ច្រើនទេមីង ខាងទ័ព?

ធី៖ កាន់ច្រើនខាងទ័ពគាត់ ។

ប៊ុនថន៖ ប្រហែលជាប៉ុន្មាន?

ធី៖ មិនដឹងប៉ុន្មានទេ ។

ប៊ុនថន៖ ដល់ពាន់នាក់ទេ?

ធី៖ មិនដល់ពាន់ទេ ត្រឹម២-៣រយហ្នឹង ។

ប៊ុនថន៖ មីងមកខាងព្រំដែនថៃនេះ មីងនៅម្តុំណាវិញ?

ធី៖ នៅម្តុំច«១» ច«២» ។

ប៊ុនថន៖ ហើយសព្វថ្ងៃគេហៅអីវិញ?

ធី៖ សព្វថ្ងៃគេហៅថ្មដារ ។

ប៊ុនថន៖ ហេតុអីបានជាគេដាក់ច«១» ច«២»?

ធី៖ អត់ដឹងដែរ ។

ប៊ុនថន៖ គេហៅអញ្ចឹងហ្នង?

ធី៖ ចា៎! នៅព្រំប្រទល់ថៃ ។

ប៊ុនថន៖ មីងមកដល់បានរយៈពេលប៉ុន្មានបាន ពូជល ហ្នឹងគាត់មកដល់ដែរ?

ធី៖ ខ្ញុំមកយូ ខ្ញុំមកនៅនេះឡើងយូហើយហ្នឹង ខ្ញុំការហើយបានគាត់មក ។

ប៊ុនថន៖ អញ្ចឹងមីងទៅនោះគេបែងចែកយ៉ាងម៉េចដែរ កាលទៅដល់ដំបូង ទៅដល់ថ្មដារហ្នឹង?

ធី៖ ទៅដល់ហ្នឹងគេប្រមូលយើងទៅនៅកន្លែងជីកជញ្ជូន ជីកជញ្ជូនទំព ជីកគ្រាប់ជីកអីយកទៅឲ្យទំពវ៉ៃ ។

ប៊ុនថន៖ ហើយកងមីងមានប៉ុន្មាននាក់ទាំងអស់ កងជីកជញ្ជូន?

ធី៖ កងជីកជញ្ជូនគិតទៅមួយក្រុម១២នាក់ពេញៗ ។

ប៊ុនថន៖ ទាំងអស់ប៉ុន្មានក្រុម?

ធី៖ ១២ក្រុម នៅមួយកងរយៗ ច្រើនណាស់កងជីកជញ្ជូន ។

ប៊ុនថន៖ អញ្ចឹងទាំងអស់១០០នាក់ជាង?

ធី៖ ចា៎!

ប៊ុនថន៖ ហើយអ្នកណាដូចថាអ្នកមើលគ្រប់គ្រងទូទៅ?

ធី៖ កាលហ្នឹងខ្ញុំនៅជាមួយ បងរ៉ុម បងសេង សំអាត ហ្នឹង ។

ប៊ុនថន៖ អ៎! មីងប្រធានឃុំហ្នឹង?

ធី៖ ចា៎! ខ្ញុំនៅជាមួយគាត់ហ្នឹង ។

ប៊ុនថន៖ ហើយគាត់ជាអ្នកមើល?

ធី៖ ចា៎! គាត់មើលខាងខុសត្រូវ ខាងជីកជញ្ជូន ។

ប៊ុនថន៖ ចុះការងារយ៉ាងម៉េចដែរមីង?

ធី៖ ការងារមានអី យើងជីកជញ្ជូនឲ្យទំព ពេលគេត្រូវការគ្រាប់ឲ្យទំពយើងឡើងយកមកឲ្យគេទៅ ។

ប៊ុនថន៖ ទៅដល់ណាខ្លះមីង?

ធី៖ ជីកឆ្ងាយជិតដែរ ។

ប៊ុនថន៖ តែទៅដល់កន្លែងណាខ្លះមីងមានចាំទេ?

ធី៖ ខ្ញុំជីកអត់ឆ្ងាយប៉ុន្មានទេ ខ្ញុំជីកតែត្រឹមផ្លូវហ្នឹងទៅ៥៦ហ្នឹង ។

ប៊ុនថន៖ រយៈពេលប៉ុន្មានថ្ងៃពេលមកម្ដងៗ?

ធី៖ មកពីព្រំដែនមកហ្នឹងមានរយៈមួយអាទិត្យពីរអាទិត្យ ដេកផ្លូវដេកអីហ្នឹង ។

ប៊ុនថន៖ យើងដើរហ្នឹង ឬក៏?

ធី៖ ដើរ ។

ប៊ុនថន៖ អត់មានអី?

ធី៖ មានឡានមកពីណា ដើរកាត់ព្រៃហ្នឹង ។

ប៊ុនថន៖ អញ្ចឹងយើងមកហ្នឹងមានស្បៀងមានអីហូបទេ?

ធី៖ មាន យើងស្ពាយអង្ករយកមកឲ្យទ័ពហូប ។

ប៊ុនថន៖ ម្ដងប៉ុន្មាននាក់មីង?

ធី៖ មកម្ដង២-៣រយ ។

ប៊ុនថន៖ ២-៣រយនាក់?

ធី៖ ចា៎!

ប៊ុនថន៖ ស្បៀងហ្នឹងដឹកជញ្ជូនចេញពីណាវិញ?

ធី៖ យកមកពីព្រំដែន ។

ប៊ុនថន៖ ខាងខ្មែរឬក៏ខាងថៃ?

ធី៖ កាលហ្នឹងខាងចិនគេជំនួយមកតាមព្រំដែនថៃ ឆ្លងកាត់ថៃ ។

ប៊ុនថន៖ ចូលទៅយកពីថៃមក ឬក៏គេនៅខាងខ្មែរមីង?

ធី៖ ថៃគេយកមក យើងមានយើងនៅមាត់សមុទ្រហ្នឹង អ្នកទាក់ទងថៃហ្នឹង គេនៅទាក់ទងហ្នឹង ដល់ពេលចិនដឹកមកអ្នកទាក់ទងយើងនៅថៃហ្នឹងគេយកមក ។

ប៊ុនថន៖ ពីណាអ្នកទាក់ទង អ្នកទំនាក់ទំនងហ្នឹង?

ធី៖ អ្នកទំនាក់ទំនងកាលហ្នឹងពួកអ្នកនៅកន្លែងតាហ្នឹងឯង តាពត ហ្នឹង ។

ប៊ុនថន៖ ឈ្មោះអីមីង មីងមានចាំទេ?

ធី៖ ខ្ញុំអត់ចាំស្គាល់គេផង ទាល់តែសួរតាៗបានគាត់ស្គាល់ សួរអ៊ីយ៉ង់អ៊ីអីហ្នឹងគាត់ស្គាល់ ។

ប៊ុនថន៖ ហើយដូចថាមីងឡើងឆ្ងាយៗមកអញ្ចឹង ដូចថាមានឈឺមានគ្រោះថ្នាក់មានអីទេ?

ធី៖ មាន មានគ្រុនឈឺអញ្ចឹងទៅយើងជួយគ្នា ហើយដូចថាមានប៉ះទាហានប៉ះអីវ៉ៃគ្នាអញ្ចឹងទៅ ។

ប៊ុនថន៖ ពីណាវ៉ៃជាមួយពីណាមីង?

ធី៖ វ៉ៃជាមួយអ្នកច្បាំងជាមួយគ្នាហ្នឹង ជាមួយទាហានហ៊ុន សែន ហ្នឹង ។

ប៊ុនថន៖ ដែលមានគ្រោះថ្នាក់ទេមីង?

ធី៖ មាន ពេលយើងវ៉ៃហ្នឹងត្រូវហើយ ។

ប៊ុនថន៖ មានស្លាប់មានអីទេមីង?

ធី៖ មាន ។

ប៊ុនថន៖ ចុះមីងការឆ្នាំប៉ុន្មាន?

ធី៖ ខ្ញុំការឆ្នាំប៉ុន្មានទេ ឆ្នាំប៉ុន្មានទេខ្ញុំភ្លេចដែរហើយ ។

ប៊ុនថន៖ មីងនៅកន្លែងដីកជញ្ជូនបានរយៈពេលប៉ុន្មានបានមានគ្រួសារ?

ធី៖ នៅយូដែរហ្នឹង ។

ប៊ុនថន៖ គ្រួសារមីងអ្នកធ្វើទ័ពដែរ?

ធី៖ ចាំ! ធ្វើទ័ពដែរ ។

ប៊ុនថន៖ គាត់នៅខាងណាវិញ ហើយនៅជាមួយពីណា?

ធី៖ កាលមុនគ្រួសារខ្ញុំគេនៅខាងជើង ដល់ពេលហើយគេផ្លាស់មកនៅហ្នឹង មកនៅវៃជាមួយពួកខ្ញុំហ្នឹងបានយកគ្នានៅហ្នឹង ការនៅហ្នឹង ។

ប៊ុនថន៖ ខាងជើងហ្នឹងខាងណាវិញ?

ធី៖ ខាងព្រះវិហារហ្នឹងឯង ខាងឧត្ដរមានជ័យអីហ្នឹង គាត់នៅខាងហ្នឹង ។

ប៊ុនថន៖ ហើយគាត់ផ្លាស់មកបានជួបមីង?

ធី៖ ចាំ!

ប៊ុនថន៖ ចុះខាងទ័ពពីណាអ្នកគ្រប់គ្រង?

ធី៖ មេទ័ពគេ ។

ប៊ុនថន៖ ពីណាគេមីង?

ធី៖ ខ្ញុំមិនសូវស្គាល់គេអស់ទេ ។

ប៊ុនថន៖ អត់ចាំឈ្មោះ?

ធី៖ ចាំ!

ប៊ុនថន៖ ចុះពេលមីងការហើយហ្នឹង ពូផល គាត់ទៅក្រោយហ្នឹងគាត់ខាងអីវិញមីង?

ធី៖ មិនដឹងគាត់ធ្វើអីផង គាត់ឡើងទៅលើ ។

ប៊ុនថន៖ កាលទៅជួបមីង?

ធី៖ ទៅជួបនៅនេះហ្នឹង គាត់មកវិញមកជួបនៅនេះហ្នឹង ។

ប៊ុនថន៖ អ៎! នៅវាលវែងនេះទេ?

ធី៖ ចាំ!

ប៊ុនថន៖ អត់មានជួបនៅកន្លែងដីកជញ្ជូនទេ?

ធី៖ អត់ទេ ។

ប៊ុនថន៖ ហើយមីងនៅខាងដីកជញ្ជូនហ្នឹងដល់ឆ្នាំណា?

ធី៖ ខ្ញុំនៅ ចូលតាំងពី៨១ ។

ប៊ុនថន៖ ៨១រហូតដល់ឆ្នាំប៉ុន្មាន?

ធី៖ ខ្ញុំការ៨០ប៉ុន្មានទេ ដូចជា៨៨ ។

ប៊ុនថន៖ ហើយមីងនៅហ្នឹងរហូត ឬក៏មានផ្លាស់ទៅណាទៀត?

ធី៖ អត់ទេ នៅតែព្រំដែនហ្នឹងអត់មានផ្លាស់ទៅណាផង ។

ប៊ុនថន៖ នៅថ្មដាររហូត?

ធី៖ នៅកន្លែងតាម១ថ្មដារហ្នឹង នៅដល់ពេលគេត្រូវគ្នាមួយវគ្គហ្នឹងខ្ញុំឡើងមកនៅឯសំឡូត ដល់ពេលគេត្រូវគ្នាហើយខ្ញុំឡើងនៅសំឡូត ដល់ពេលគេបះបោលមួយសារទៀតបានខ្ញុំទៅព្រំដែនថៃហ្នឹងបានឡើងមកនេះ ។

ប៊ុនថន៖ ទៅខាងសំឡូតហ្នឹងផ្លាស់ទាំងកងទៅទាំងអស់ហ្មង ឬក៏ទៅតែមីង?

ធី៖ ប្រជាជនឡើងមកនៅសំឡូតហ្នឹងទាំងអស់ ។

ប៊ុនថន៖ ហេតុអីបានជាគេផ្លាស់ទៅហ្នឹងមីង?

ធី៖ កាលហ្នឹងចុះយើងនៅហ្នឹងស្រាប់ហើយ នៅព្រំដែនហ្នឹង ។

ប៊ុនថន៖ ចុះមីងទៅសំឡូត ហើយនៅថ្មដារហ្នឹងពីណានៅវិញ?

ធី៖ ថ្មដារហ្នឹងគេនៅហ្នឹងស្រាប់ ពួកខ្ញុំនៅខាងសំឡូតហ្នឹង ។

ប៊ុនថន៖ ហើយទៅហ្នឹងមីងនៅខាងកងដឹកជញ្ជូនដដែល នៅសំឡូតហ្នឹង?

ធី៖ អត់ទេ កាលហ្នឹងខ្ញុំការហើយនៅជាប្រជាជនហ្នឹង ។

ប៊ុនថន៖ អញ្ចឹងអ្នកការគេឲ្យទៅនៅសំឡូត?

ធី៖ ឲ្យតែអ្នកការហ្នឹងគេបញ្ចូលជាប្រជាជនអស់ហើយ អត់មាននៅជានារីទេ អត់មាននៅកងនារីអីទៀតទេ នៅតាមទ័ពវិញហើយ ការជាមួយទ័ពនៅអង្គភាពទ័ពវិញហើយ ។

ប៊ុនថន៖ ចុះពូគាត់ផ្លាស់ទៅទេ?

ធី៖ ដល់ពេលការហើយខ្ញុំមកតាមកងគាត់វិញហ្នឹង ម៉ាដូរហ្នឹងកងគាត់ ការហើយចូលខាងទ័ពធ្វើប្រពន្ធទ័ពវិញ ឈប់នៅនារីហើយ ។

ប៊ុនថន៖ គ្រួសារកងទ័ពវិញ?

ធី៖ ចា៎!

ប៊ុនថន៖ មីងទៅនៅសំឡូតបានយូទេមីង?

ធី៖ នៅបានយូដែរហ្នឹង នៅបានកូន៤នាក់ ។

ប៊ុនថន៖ នៅបានកូន៤នាក់?

ធី៖ ចា៎! មកកើតនៅនេះមួយ ។

ប៊ុនថន៖ នៅសំឡូតហ្នឹងខាងណាគ្រប់គ្រងមីង?

ធី៖ កាលហ្នឹងខាងមេស្រុកសំឡូតហ្នឹងគឺ តាម៉ុន ។

ប៊ុនថន៖ តាម៉ុន ហ្នឹងគាត់ខាង?

ធី៖ គាត់ខាងចៅហ្វាយស្រុក ។

ប៊ុនថន៖ ស្អីម៉ុន?

ធី៖ ខ្ញុំអត់ដឹងផង ។

ប៊ុនថន៖ គាត់នៅរស់ទេ?

ធី៖ គាត់នៅរស់តើ ។

ប៊ុនថន៖ នៅណាវិញឥលូវ?

ធី៖ នៅសំឡូតហ្នឹង ។

ប៊ុនថន៖ ចុះដូចថាកាន់ខាងគ្រប់គ្រងទូទៅហ្នង?

ធី៖ ខ្ញុំអត់ដឹងផង ។

ប៊ុនថន៖ ខាងកងទ័ពអី?

ធី៖ ខ្ញុំអត់ស្គាល់ទេ ។

ប៊ុនថន៖ មីងទៅសំឡូតហ្នឹងធ្វើអីវិញ?

ធី៖ ធ្វើស្រែ ។

ប៊ុនថន៖ ធ្វើស្រែរួមឬក៏?

ធី៖ ធ្វើឯកជន ។

ប៊ុនថន៖ ហើយពេលយើងធ្វើបានហ្នឹងមានលក់ទេ ឬមួយក៏សម្រាប់តែហូបទេ?

ធី៖ សម្រាប់តែហូបហ្នឹង ធ្វើគ្រាន់ម៉ាហូបៗអត់មានបានលក់បានដូរអីផង ។

ប៊ុនថន៖ ហើយមីងឆ្នាំប៉ុន្មានបានមីងផ្លាស់មកនៅនេះ?

ធី៖ មកនៅនេះឆ្នាំ៩៩ ហើយយើងបះបោលមួយសារក្រោយនេះបានខ្ញុំមកនេះ ។

ប៊ុនថន៖ ខាងខ្មែរក្រហមបញ្ជូនមក ឬក៏យើងមកនៅហ្នង?

ធី៖ យើងមកនៅ ។

ប៊ុនថន៖ មីងថាបះបោលហ្នឹង បះបោលម៉េចទៅ?

ធី៖ ដូចថាជិនាន់ហ្នឹងគេមិនត្រូវគ្នា ដែលជិនាន់វៃគ្នាហើយមិនត្រូវគ្នា ។

ប៊ុនថន៖ សមារណកម្ម?

ធី៖ ចា៎! សមារណកម្ម ដល់ក្រោយមកមានអ្នកបះបោលមួយសារទៀត ។

ប៊ុនថុនៈ បះបោលយ៉ាងម៉េចមីង?

ធីៈ បះបោលដូចថាចង់ក្បត់គ្នាមួយសារទៀតណា៎ គេប្រមូលជាប្រជាជនយកទៅម្ខាងហើយវ៉ៃគ្នាទៀតទៅ ។

ប៊ុនថុនៈ វ៉ៃជាមួយពីណា?

ធីៈ វ៉ៃជាមួយពួកខាងហ៊ុន សែន ហ្នឹងមួយសារទៀត ដល់ពេលវ៉ៃហើយគេសម្របសម្រួលគ្នាត្រូវគ្នាវិញខ្ញុំឡើងមកនេះវិញមក ខ្ញុំឈប់នៅនោះទៅ ។

ប៊ុនថុនៈ ឈប់នៅសំឡូតហ្នឹង?

ធីៈ ចា៎!

ប៊ុនថុនៈ ហើយមីងមានបានទៅថៃទេ?

ធីៈ ទៅតើ ខ្ញុំទៅនៅថៃ ។

ប៊ុនថុនៈ ទៅនៅថៃបានរយៈពេលប៉ុន្មាន?

ធីៈ កាលពីជំនាន់វ៉ៃគ្នាខ្ញុំនៅតែថៃហ្នឹង ដល់ពេលក្រោយមកពេលដែលគេបះបោលហ្នឹងនៅបានមួយឆ្នាំ ។

ប៊ុនថុនៈ នៅថៃហ្នឹងមីង?

ធីៈ ចា៎! នៅកន្លែងធ្លាប់នៅហ្នឹង ។

ប៊ុនថុនៈ គេហៅអីវិញកន្លែងមីងធ្លាប់នៅហ្នឹង?

ធីៈ ម្តុំខ្ញុំនៅគេហៅផ្កាល្ហុង ។

ប៊ុនថុនៈ ជំរុំមែនមីង?

ធីៈ ជំរុំចំការល្ហុង ។

ប៊ុនថុនៈ នៅក្នុងខេត្តអីវិញមីង?

ធីៈ អត់ដឹងផង អត់ដឹងខេត្តអីទេព្រោះស្រុកថៃ ។

ប៊ុនថុនៈ អញ្ចឹងមីងទៅនៅតែមីងទេ ហើយគ្រួសាររបស់មីងទៅទេ? [

ធីៈ ទៅទាំងអស់គ្នា ប៉ុន្តែទៅហើយគេឡើងមកវ៉ៃវិញ ប៉ុន្តែគ្រួសារខ្ញុំគាត់មានវ៉ៃអីគាត់ គាត់ដាច់ជើងយូហើយ ។

ប៊ុនថុនៈ គាត់ពិការដែរ?

ធីៈ ចា៎!

ប៊ុនថុនៈ ពិការដោយសារអីមីង?

ធីៈ ជាន់មីន ។

ប៊ុនថនៈ ហើយមីងនៅរហូតដល់ឆ្នាំ៩៩បានមីងមកនៅនេះហ្នង?

ធីៈ ចា៎!

ប៊ុនថនៈ ពេលមីងមកដល់ដីបូងខាងដីអីគេរៀបចំយ៉ាងម៉េចដែរ គេចែកឲ្យឬមួយក៏យើងចាប់?

ធីៈ យើងមកដីបូងយើងចាប់ ចាប់យកចំការយកអីអញ្ចឹង ប៉ុន្តែតាមផ្លូវនេះគេចែកឲ្យយើងនៅ ប៉ុន្តែតាមចំការតាមអីយើងចាប់យកខ្លួនយើង ។

ប៊ុនថនៈ គេចែកឲ្យមួយគ្រួសារប៉ុន្មានមីង?

ធីៈ ក្បាល២០ ។

ប៊ុនថនៈ បណ្ដោយ?

ធីៈ កាលហ្នឹងបណ្ដោយ៥០ គេចែកឲ្យប៉ុណ្ណឹងៗ ។

ប៊ុនថនៈ គេចែកឲ្យជាប់ៗផ្លូវហ្នឹងហ្នង?

ធីៈ ចា៎! គ្រាន់តែដីចំការយើងចាប់ខ្លួនយើង ។

ប៊ុនថនៈ ចាប់ប៉ុន្មាន យើងចាប់យកប៉ុន្មាន?

ធីៈ យកប៉ុន្មានយកទៅ ប៉ុន្តែឥលូវមិនដឹងម៉េចទេយើងមិនដឹងដែរ?

ប៊ុនថនៈ ហើយមីងចាប់បានប៉ុន្មាន?

ធីៈ ខ្ញុំចាប់បានច្រើនដែរហ្នឹង ហើយចែកកូន ។

ប៊ុនថនៈ បានទាំងអស់ប៉ុន្មានហិចតា?

ធីៈ ខ្ញុំចាប់ពីរបីកន្លែង តែឆ្ងាយៗដល់ហើយខ្ញុំលក់ឲ្យគេអស់ខ្លះទៅ ។

ប៊ុនថនៈ ហើយឥលូវនៅសល់ទាំងអស់ប៉ុន្មានមីង?

ធីៈ ឥលូវនៅសល់ចំការប្រហែលជា១០ហាត់ ។

ប៊ុនថនៈ ហើយមកដល់ដីបូងមីងធ្វើអីវិញ?

ធីៈ មកកាប់ធ្វើចំការហ្នឹង អត់មានធ្វើអីផង គ្រាន់តែកាប់ព្រៃធ្វើចំការហ្នឹង ។

ប៊ុនថនៈ ចុះគ្រួសាររបស់មីងលែងធ្វើទ័ពហើយ?

ធីៈ អត់ធ្វើផង ឈប់ធ្វើហើយ ។

ប៊ុនថនៈ ហើយគាត់មានបានរបបបានអីទេមីង?

ធីៈ អត់ដែលបានផងគេកាត់ របបគាត់នៅសំឡូត ឈ្មោះគាត់នៅសំឡូតគេស៊ីអស់ យើងអត់ចូលទៅ ។

ប៊ុនថនៈ ហើយរាល់ថ្ងៃហ្នឹងដាច់អត់មានរបបមានអីទេ?

ធីៈ អត់មានទេ ។

ប៊ុនថន៖ ហើយចូលមកដំបូងហ្នឹងមានផ្លូវនេះនូវ?

ធី៖ ផ្លូវហ្នឹងមានតែផ្លូវចាស់ កាលជំនាន់សង្គ្រាម ។

ប៊ុនថន៖ ហើយឡានអីបររួចទេ?

ធី៖ អត់បានទេ អត់ដែលបានឡានបរផងជំនាន់ហ្នឹង កាលមកដល់ដំបូងសុទ្ធតែព្រៃហ្នឹង ដើរតែ ភាវមីនហ្នឹង ។

ប៊ុនថន៖ នៅនេះព្រៃទាំងអស់ឬក៏ម៉េច?

ធី៖ ព្រៃទាំងអស់ ។

ប៊ុនថន៖ ស្រឡះដូចរាល់ថ្ងៃទេ?

ធី៖ អត់ទេ សុទ្ធតែព្រៃណែនទាំងអស់ ។

ប៊ុនថន៖ ហើយចូលដំបូងមានគ្រួសារច្រើនទេមីង?

ធី៖ មកដំបូងច្រើនដែរ តែគេនៅតាមៗចំការគេ មានគេមកនៅហ្នឹងមុន ។

ប៊ុនថន៖ មានមុនហ្នឹងទៀត?

ធី៖ មាន ម៉ាជួរវង្វង់មូលហ្នឹងគេនៅហ្នឹងមុនខ្ញុំ នៅតាំងពីនៅវៃគ្នា ។

ប៊ុនថន៖ ប៉ុន្តែគ្រួសារប្រជាជនទេ មិនមែនកងទ័ពទេ?

ធី៖ គ្រួសារកងទ័ព ភាគច្រើនគ្រួសារកងទ័ពមកនៅហ្នឹង សុទ្ធតែកងទ័ព ប៉ុន្តែឥលូវអត់មានទ័ពទេ អស់ហើយ មានតែប្រជាជន ។

ប៊ុនថន៖ ហើយដូចថារស់នៅយ៉ាងម៉េចដែរ ធ្វើតែចំការឬក៏រកស៊ីដែរ?

ធី៖ អត់មានដួញអីផង ធ្វើតែចំការ ។

ប៊ុនថន៖ ហើយចុះប្រជាជននៅហ្នឹង?

ធី៖ ប្រជាជននៅហ្នឹងដំបូងគេធ្វើចំការដូចគ្នា អត់មានដួញទៅណាទេ ប៉ុន្តែឥលូវមានផ្លូវអញ្ចឹង គេដាំនេះដាំនោះដើម្បីលក់ដូរ ។

ប៊ុនថន៖ ហើយធ្វើទុកហូបខ្លួនឯងទៅ?

ធី៖ ចា៎!

ប៊ុនថន៖ ហើយសព្វថ្ងៃមានកូនប៉ុន្មាននាក់?

ធី៖ ខ្ញុំមានកូន៥នាក់ ។

ប៊ុនថន៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ធី៖ ប្រុស២នាក់ ស្រី៣នាក់ ។ៈ

ប៊ុនថន៖ ហើយមានគ្រួសារនូវ?

ធី៖ មានគ្រួសារ២នាក់ កូនបង ហើយនឹងកូនបន្ទាប់បង ។

ប៊ុនថន៖ ហើយសព្វថ្ងៃមីងធ្វើអីដែរ?

ធី៖ ខ្ញុំធ្វើចំការ ។

ប៊ុនថន៖ ចំការអី?

ធី៖ ដាំសណ្តែកដាំស្រូវ ។

ប៊ុនថន៖ ហើយមីង ដូចថាពីមុនសមារណកម្មគេមកនៅក្រោយមីងមកនៅអញ្ចឹង ដូចថាមានប្រែកអីទេ តំបន់ហ្នឹងហើយនឹងជីវភាពរស់នៅ?

ធី៖ វាប្រែកត្រង់ថាគេធ្វើផ្លូវធ្វើអីឲ្យយើងបាននៅ យើងរកខ្លួនយើងផងអីផងទៅ ។

ប៊ុនថន៖ មីងសព្វថ្ងៃនេះយើងមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានដូចជា នួន ជា, អៀង ធារិទ្ធ ហើយនឹងខៀវ សំផន អីដែលជាមេដឹកនាំខ្មែរក្រហមធំៗ ។

ធី៖ អត់ដឹង ។

ប៊ុនថន៖ ហើយឥលូវមានតុលាការខ្មែរហើយនឹងតុលាការអន្តរជាតិ យូអិនហ្នឹងគេបង្កើតតុលាការមួយ ហើយមីងយល់យ៉ាងម៉េចដែរមីង បើតាមយោបល់មីង?

ធី៖ មិនដឹងម៉េច ។

ប៊ុនថន៖ អត់អីទេ អញ្ចឹងអ្នកមីងមានអីចង់បន្ថែមនៅអ្វីដែលមីងបានចាំ ហើយមីងមិនទាន់បាននិយាយ?

ធី៖ មិនដឹងបន្ថែមអីទេ ព្រោះមិនដឹងអីផង ។

ប៊ុនថន៖ អញ្ចឹងខ្ញុំអរគុណមីងច្រើន ។

ធី៖ ចា៎!